**សេចក្តីប្រកាសព័ត៌មានៈ**

## អ្នកជំនាញបានកោះប្រជុំដើម្បីរៀបចំអនាគតវាយនភណ្ឌវិលជុំនៅកម្ពុជា

**រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា៖ ថ្ងៃទី23 ខែឧសភា ឆ្នាំ2023៖ អង្គការ Fashion Agenda (GFA) អង្គការសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) និងមជ្ឈមណ្ឌលធុរកិច្ចដែលមានទំនួលខុសត្រូវ ដែលរៀបចំឡើងដោយសភាពាណិជ្ជកម្មអឺរ៉ុប បានកោះប្រជុំអ្នកជំនាញការល្បីៗ និងភាគីពាក់ព័ន្ធជាង 100 នាក់ នៅថ្ងៃទី16 ខែឧសភា ដើម្បីធ្វើការពិភាក្សាអំពីស្ថានភាពបច្ចុប្បន្ននៃសំណល់វាយនភណ្ឌនៅក្នុងប្រទេស និងចាត់វិធានការបន្ទាប់ទៀតសម្រាប់អនាគតវិលជុំ។**

នៅកិច្ចប្រជុំនៅក្រោមប្រធានបទ "**ឱកាសសំណល់វាយនភណ្ឌសម្រាប់វាយនភណ្ឌ កាត់ដេរ និងស្បែកជើងវិលជុំនៅកម្ពុជា** ដើរតួនាទីជាកម្មវិធីអន្តរទំនាក់ទំនងដើម្បីលើកឡើងអំពីប្រធានបទសំណល់វាយនភណ្ឌពីរោងចក្រនៅកម្ពុជា និងពិភាក្សាអំពីជម្រើស ដំណោះស្រាយ និងឱកាសសម្រាប់ដំណើរការឆ្ពោះទៅរកវិធីសាស្រ្តវិលជុំបន្ថែមទៀត។ មានការប៉ាន់ប្រមាណថា ឧស្សាហកម្មវាយនភណ្ឌ កាត់ដេរ និងស្បែកជើងបង្កើតឱ្យមានសំណល់វាយនភ័ណ្ឌប្រមាណជា 140,0000 តោនក្នុងមួយឆ្នាំ[1] ដែលភាគច្រើននៃសំណល់ទាំងនោះត្រូវបានចាត់ចែងកែច្នៃដោយមិនមានការគ្រប់គ្រង និងពុំមានចីរភាព ដុតចោល ឬយកទៅចោលនៅទីលានចាក់សំរាម៖ ដែលបង្កឱ្យមានគ្រោះថ្នាក់ទាំងចំពោះបរិស្ថាន និងមនុស្ស។

កិច្ចប្រជុំនោះបានធ្វើការកត់សម្គាល់លើការចាប់ផ្តើមឱ្យមានគំនិតផ្តួចផ្តើមសកម្មដើម្បីគាំទ្រដល់ការបង្កើតប្រព័ន្ធកែច្នៃនៅកម្ពុជាតាមរយៈការគាំទ្រគម្រោងសាកល្បងដែលអាចឱ្យមានការបែងចែកប្រភេទសំណល់ត្រឹមត្រូវ និងកែច្នៃសំណល់វាយនភណ្ឌ ហើយចុងក្រោយ បង្វែរសំណល់ទាំងនោះ

[1] GIZ គណនាដោយប្រើស្ថិតិនាំចូលក្រណាត់ពីអគ្គនាយកដ្ឋានគយកម្ពុជា

ចេញពីទីលានចាក់សំរាម ឬកន្លែងដុតចោល។ អង្គការ GFA និង GIZ បច្ចុប្បន្ន កំពុងឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធសម្រាប់គម្រោង**ភាពជាដៃគូសម្លៀកបំពាក់វិលជុំកម្ពុជា** (Circular Fashion Partnership Cambodia) ដែលជាផ្នែកមួយនៃ**វេទិកាសម្លៀកបំពាក់វិលជុំសកល** (Global Circular Fashion Forum) (GCFF) ដែលមានគោលដៅលើកទឹកចិត្តឱ្យមានសកម្មភាពក្នុងស្រុកនៅប្រទេសផលិតវាយនភណ្ឌពន្លឿន និងពង្រីកការកែច្នៃសំណល់វាយនភ័ណ្ឌបន្ទាប់ពីប្រើប្រាស់នៅក្នុងឧស្សាហកម្មរួច។

សមាសភាពចូលរួម រួមមានតំណាងមកពីរោងចក្រ ម្ចាស់ម៉ាកយីហោ រោងចក្រកែច្នៃ និងបច្ចេកវិទ្យាកែច្នៃ អ្នកចាត់ចែងទុកដាក់សំណល់វាយនភណ្ឌ និងរដ្ឋាភិបាលដែលរួមគ្នាតំណាងឱ្យឧស្សាហកម្មសម្លៀកបំពាក់សកល និងកែច្នៃនៅកម្ពុជា។ អ្នកចូលរួមបានស្តាប់ការពន្យល់បកស្រាយពីសំណាក់វាគ្មិនល្បីៗចំនួន 22 រូប ដែលក្នុងនោះរួមមាន **ឯកឧត្តម សឹម ណារ៉ា** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ **ឯកឧត្តម ប៉ាក សុខារ៉ាវុធ** អនុរដ្ឋលេខាធិការក្រសួងបរិស្ថានកម្ពុជា និងតំណាងមកពី**កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ** Fashion for Good, Crystal International Group, The Hong Kong Research Institute of Textiles and Apparel, TAFTAC (**សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើងនិងផលិតផលធ្វើដំណើរ**), Global Fashion Agenda, GIZ, Euro Cham, PricewaterhouseCoopers Pvt. Ltd. និងអ្នកចូលរួមជាច្រើនផ្សេងទៀត។

វាគ្មិនបានពិភាក្សាអំពីការផ្សព្វផ្សាយព័ត៌មានអំពីបច្ចេកវិទ្យាកែច្នៃ គ្រឿងលើកទឹកចិត្តធុរកិច្ច ការសិក្សា និងការអនុវត្តល្អៗពីប្រទេសដទៃ ច្បាប់ ការញែកសំណល់វាយនភណ្ឌ ទិន្នន័យ ការពិចារណាផ្នែកសង្គមសម្រាប់អន្តរកាលឆ្ពោះទៅរកការវិលជុំ និងការកែសម្រួលលើដំណោះស្រាយឱ្យត្រូវតាមបរិបទនៅកម្ពុជា។ កិច្ចប្រជុំនោះក៏មានកម្មវិធីដើរបង្ហាញម៉ូតសម្លៀកបំពាក់កម្ពុជា ដែលនាំដោយយុវជន ដោយបង្ហាញអំពីការរចនាម៉ូតសម្លៀកបំពាក់ដែលផលិតពីសម្ភារកែច្នៃឡើងវិញផងដែរ។

លោកស្រី **Federica Marchionni នាយកប្រតិបត្តិអង្គការ Global Fashion Agenda បានមានប្រសាសន៍ថា៖** "ភាពជោគជ័យយ៉ាងច្រើនពីកិច្ចប្រជុំ GCFF នៅកម្ពុជាគឺជាការធ្វើតេស្តសាកល្បងចំពោះអានុភាពនៃចក្ខុវិស័យរួម។ នៅអង្គការ Global Fashion Agenda យើងពិតជាចង់ផ្លាស់ប្តូរកម្លាំងចលនាករ និងរៀនពីកិច្ចប្រជុំនេះ ដោយសារយើងចាប់ផ្តើមរៀបចំគម្រោងភាពជាដៃគូសម្លៀកបំពាក់វិលជុំនៅកម្ពុជា។ ការរៀនសូត្រដ៏សំខាន់មួយពីកិច្ចប្រជុំនេះគឺជាតម្រូវការបង្កើតរោងចក្រកំណាត់ប្រភេទសំណល់ក្នុងស្រុក ដើម្បីចាប់ និងញែកសំណល់ដែលអាចប្រើបានពីសំណល់វាយនភណ្ឌក្រោយចេញពីឧស្សាហកម្ម ដែលបង្កើនតម្លៃដល់រោងចក្រកែច្នៃវាយនភណ្ឌ។ ក្នុងដំណើរការទាំងមូលនេះ យើងនឹងសហការជាមួយដៃគូរបស់យើងដើម្បីធានាថា យើងបានដាក់បញ្ចូលគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ និងត្រូវដឹងពីបរិបទក្នុងស្រុកដែលមានលក្ខណៈខុសៗគ្នា។"

**បណ្ឌិត Gunter Riethmacher នាយកប្រចាំប្រទេសនៃអង្គការសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់កម្ពុជា បានលើកឡើងថា** "ការកែច្នៃសំណល់វាយនភណ្ឌក្រោយចេញពីឧស្សាហកម្មមិនទាន់អស់សក្តានុពលនៅឡើយទេដោយសារតែបញ្ហាប្រឈមនានាដូចជាសំណល់ក្រណាត់ដាក់ឡូកឡំគ្នា បញ្ហាផ្នែកញែកក្រណាត់សំណល់ និងកង្វះសមត្ថភាពកែច្នៃក្នុងស្រុក។ គម្រោងសាកល្បងដែលអនុវត្តដោយអង្គការ GIZ ជាមួយនឹងអង្គការ GFA ស្ថិតក្រោមគម្រោងភាពជាដៃគូសម្លៀកបំពាក់វិលជុំ នឹងជួយកាត់បន្ថយបញ្ហាប្រឈមនានា និងបង្ហាញថា ដំណោះស្រាយល្អអាចមានតាមរយៈការប្រមូលផ្តុំភាគីពាក់ព័ន្ធទាំងអស់នៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ត្រឹមត្រូវ។ ការលើកឡើងអំពីសំណល់វាយនភណ្ឌនឹងក្លាយជាប្រធានបទអំពីចីរភាពភាពកាន់សំខាន់សម្រាប់វិស័យទាំងមូល។"

**មជ្ឈមណ្ឌលធុរកិច្ចដែលមានទំនួលខុសត្រូវដែលរៀបចំដោយសភាពាណិជ្ជកម្មអឺរ៉ុបបានលើកឡើងថា** "ធុរកិច្ចដែលមានទំនួលខុសត្រូវមានទំនាក់ទំនងជាចម្បងជាមួយនឹងចីរភាព និងភាពវិលជុំ។ ដូច្នេះមជ្ឈមណ្ឌល RBH សូមគាំទ្រយ៉ាងពេញទំហឹងចំពោះគំនិតផ្តួចផ្តើមណាមួយដែលមានគោលដៅកែច្នៃសំណល់ក្រណាត់នៅក្នុងប្រទេសនេះ។ ឯកសារអំពីការចូលរួមចំណែកប្តេជ្ញាចិត្តថ្នាក់ជាតិ (NDC) ឆ្នាំ2020 ដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់កម្ពុជា ដែលបោះពុម្ពផ្សាយដោយក្រសួងបរិស្ថាន (MOE)

បានបង្ហាញអំពីសារសំខាន់របស់រោងចក្រកែច្នៃកណ្តាលសម្រាប់សំណល់ឧស្សាហកម្មចេញពីវិស័យកាត់ដេរ។ រោងចក្រកែច្នៃនោះគឺជាផ្នែកសំខាន់មួយនៃយុទ្ធសាស្ត្រកាត់បន្ថយសំណល់វាយនភ័ណ្ឌនៅកម្ពុជា។ មជ្ឈមណ្ឌល RBH ប្តេជ្ញាសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ដូចជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) រួមទាំងសមាគម TAFTAC ដើម្បីធានាឱ្យការអនុវត្តគម្រោងនេះទទួលបានជោគជ័យ រួមជាមួយនឹងវិស័យឯកជន។"

គម្រោងភាពជាដៃគូសម្លៀកបំពាក់វិលជុំនៅកម្ពុជា នឹងមានគម្រោងសាកល្បងជាលើកដំបូងដើម្បីបង្កើត និងតេស្តសាកល្បងដំណើរការញែកប្រភេទវាយនភ័ណ្ឌដែលមានប្រសិទ្ធភាព ព្រមទាំងរកគំរូធុរកិច្ចពាក់ព័ន្ធច្រើនបំផុតដែលផ្តល់អត្ថប្រយោជន៍ដល់តួអង្គទាំងអស់។ គម្រោងសាកល្បងនេះកំពុងរៀបចំបង្កើតឡើង ហើយអ្នករៀបចំសូមស្វាគមន៍ចូលរួមជាមួយគម្រោងនេះដោយទទួលការចុះឈ្មោះរហូតដល់ថ្ងៃទី01 ខែកក្កដា ឆ្នាំ2023។

**ដើម្បីទទួលព័ត៌មានបន្ថែមអំពី Global Circular Fashion Forum សូមចូលទៅកាន់វេបសាយត៍៖**

www.globalfashionagenda.org

---

**កំណត់ចំណាំសម្រាប់អ្នកនិពន្ធ៖**

អាចទាញយកឯកសារនៅទីនេះ សូមបញ្ជាក់គ្រប់រូបភាពទាំងអស់ជារបស់អង្គការ GIZ។

**ទំនាក់ទំនង៖**

សម្រាប់ការសាកសួរអំពីប្រព័ន្ធផ្សព្វផ្សាយ សូមទំនាក់ទំនងមកកាន់អ៊ីមែល៖

press@globalfashionagenda.org

ដើម្បីចុះឈ្មោះសិក្សាបន្ថែមអំពីគម្រោងនេះ និង/ឬចូលរួមក្នុងគម្រោងសាកល្បងភាពជាដៃគូសម្លៀកបំពាក់វិលជុំដំណាក់កាលទីមួយនៅកម្ពុជា សូមទំនាក់ទំនង៖

លោក Shamiul Hoque ប្រធានកម្មវិធីផលប៉ះពាល់នៃអង្គការ Global Fashion Agenda

shamiul@globalfashionagenda.org

ទូរសព្ទលេខ៖ +880 17 1170 3369

លោកស្រី Kristin Sommer មន្ត្រីសម្របសម្រួលបរិស្ថាននៃអង្គការ GIZ FABRIC

kristin.sommer@giz.de

ទូរសព្ទលេខ៖ +85592354604

**អំពីវេទិកា Global Circular Fashion Forum**

Global Circular Fashion Forum (GCFF) គឺជាគំនិតផ្តួចផ្តើមថ្មីជាសកលមួយដែលបង្កើតឡើងដោយអង្គការ Global Fashion Agenda (GFA) និងផ្តល់មូលនិធិដោយអង្គការ GIZ។ GCFF មានគោលដៅលើកទឹកចិត្តឱ្យមានសកម្មភាពក្នុងស្រុកនៅប្រទេសផលិតវាយនភណ្ឌដើម្បីពន្លឿន និងពង្រីកការកែច្នៃសំណល់វាយនភណ្ឌក្រោយចេញពីឧស្សាហកម្ម ពោលគឺជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីសម្រេចបានឧស្សាហកម្មសម្លៀកបំពាក់វិលជុំអាចពង្រីកខ្លួនបានរយៈពេលវែង និងផ្លាស់ប្តូរទៅជាឧស្សាហកម្មសម្លៀកបំពាក់វិលជុំ។

GCFF កសាងបន្ថែមលើបទពិសោធន៍របស់អង្គការ GFA ជាមួយនឹងគម្រោងភាពជាដៃគូសម្លៀកបំពាក់វិលជុំ (CFP) នៅប្រទេសបង់ក្លាដែសអំឡុងឆ្នាំ2020-2021 ដែលបានបង្ហាញពីសក្តានុពលនៃការពន្លឿន និងការពង្រីកនៅក្នុងស្រុកចំពោះការកែច្នៃសំណល់វាយនភណ្ឌក្រោយចេញពីឧស្សាហកម្មដើម្បីបង្កើតវាយនភណ្ឌថ្មី។ គម្រោងនេះបានសម្របសម្រួលកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មវិលជុំរវាងរោងចក្រវាយនភណ្ឌ និងកាត់ដេរចំនួន 43 រោងចក្រកែច្នៃ 17 ភ្នាក់ងារទិញមួយ និងម្ចាស់ម៉ាកយីហោសម្លៀកបំពាក់សកលធំៗចំនួន 20។

GCFF មានបំណងបង្កើតប្រព័ន្ធអេកូបរិស្ថានចាំបាច់សម្រាប់គម្រោងភាពជាដៃគូសម្លៀកបំពាក់វិលជុំថ្នាក់ដែលដឹកនាំ និងធ្វើនៅក្នុងស្រុកដែលចាប់ផ្តើមនៅកម្ពុជា។ GCFF នឹងពិចារណាទៅលើបរិបទក្នុងស្រុកដើម្បីឱ្យស្របតាមសកម្មភាពអាទិភាពរបស់អង្គការ CFP។

**អំពីអង្គការ Global Fashion Agenda**

អង្គការ Global Fashion Agenda គឺជាអង្គការមិនរកប្រាក់ចំណេញដែលជំរុញឱ្យមានកិច្ចសហការឧស្សាហកម្មលើចីរភាពផ្នែកសម្លៀកបំពាក់ដើម្បីពន្លឿនឱ្យមានលទ្ធផល។ ជាមួយចក្ខុវិស័យអំពី

ឧស្សាហកម្មសម្លៀកបំពាក់ជាវិជ្ជមាន អង្គការជំរុញឱ្យមានសកម្មភាពតាមរយៈការកៀរគរ ជំរុញទឹកចិត្ត បង្ហាញឥទ្ធិពល និងបង្រៀនភាគីពាក់ព័ន្ធទាំងអស់។

អង្គការបាន និងកំពុងដឹកនាំចលនានេះចាប់តាំងពីឆ្នាំ2009 និងក្រោយមកបានក្លាយជាវេទិកាអន្តរជាតិដែលមានឈ្មោះបោះសំឡេងអំពីចីរភាពផ្នែកសម្លៀកបំពាក់ កិច្ចប្រជុំកំពូលស្តីពីសម្លៀកបំពាក់សកល វេទិកានវានុវត្តន៍ ការចូលរួមផ្នែកគោលនយោបាយ ការបោះពុម្ពផ្សាយអំពីភាពជាអ្នកដឹកនាំគិតវែងឆ្ងាយរួមមាន The GFA Monitor, Fashion CEO Agenda និង Fashion on Climate និងកម្មវិធីអំពីផលប៉ះពាល់រួមមាន Circular Fashion Partnership និង Global Circular Fashion Forum។

ដោយសហការជាមួយដៃគូយុទ្ធសាស្ត្ររបស់ខ្លួន BESTSELLER, Global Fashion Group, H&M Group, Kering, Nike, Ralph Lauren Corporation and Target, និង Strategic Knowledge Partner, Mckinsey & Company, Global Fashion Agenda អង្គការបានធ្វើដំណើរឆ្ពោះទៅរកអនាគតកាន់តែមានចីរភាពនៅក្នុងឧស្សាហកម្មសម្លៀកបំពាក់។ តាមរយៈការងារនេះ អង្គការ Global Fashion Agenda បានទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធរាប់ពាន់ដោយក្នុងនោះរួមមានម្ចាស់ម៉ាកយីហោ អ្នកកែច្នៃ អង្គការមិនមែនរដ្ឋាភិបាល អ្នករៀបចំគោលនយោបាយ រោងចក្រ វិនិយោគិន និងជាច្រើនទៀត។

**អំពីអង្គការ Deutsche Gesellschaft fur Internationale Zusammenarbeit (GIZ) GmbH**

GIZ គឺជាអង្គការផ្តល់សេវាសកលមួយលើផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍដោយចីរភាព និងការងារអប់រំអន្តរជាតិ។ អង្គការ GIZ មានបទពិសោធន៍ជាង 50 ឆ្នាំទៅផ្នែកជាច្រើនដូចជាការអភិវឌ្ឍសេដ្ឋកិច្ច និងការងារ ថាមពល និងបរិស្ថាន និងសន្តិភាព និងសន្តិសុខជាដើម។

GIZ FABRIC Cambodia គឺជាគម្រោងមួយដែលបំពេញតួនាទីតំណាងឱ្យក្រសួងកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) សហព័ន្ធអាល្លឺម៉ង់។ គម្រោង FABRIC គាំទ្រដល់ឧស្សាហកម្ម

វាយនភណ្ឌ និងកាត់ដេរនៅកម្ពុជា និងតំបន់ក្នុងការប្រែក្លាយទៅរកផលិតកម្មមានតម្លាភាពទាំងមនុស្ស និងបរិស្ថាន។

ដើម្បីគាំទ្រដល់ការបង្កើតឱ្យមានដំណោះស្រាយដោយចីរភាពសម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរដែលមានការប្រកួតប្រជែង គម្រោងសហការជាមួយតួអង្គរដ្ឋ ឯកជន និងសង្គមស៊ីវិលលើបញ្ហាសង្គម និងបរិស្ថាន។

**<u>អំពីមជ្ឈមណ្ឌលធុរកិច្ចដែលមានទំនួលខុសត្រូវ</u>**

**<u>អំពីមជ្ឈមណ្ឌលធុរកិច្ចដែលមានទំនួលខុសត្រូវ</u>**គឺជាកន្លែងផ្តល់សេវាដោយឥតគិតថ្លៃសម្រាប់ធុរកិច្ចក្នុងស្រុកនៅកម្ពុជាដែលបង្កើតឡើង និងរៀបចំដោយសភាពាណិជ្ជកម្មអឺរ៉ុបរួមសហការជាមួយអង្គការសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ FABRIC) និងសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC)។ មជ្ឈមណ្ឌលនេះផ្តល់ព័ត៌មាន និងសេវាពិគ្រោះយោបល់អំពីការអនុវត្តធុរកិច្ចដោយចីរភាព និងផ្តោតលើការធ្វើឱ្យមានតម្លាភាពទិន្នន័យនៅក្នុងវិស័យនោះ។